| ផែនការអនុវត្តរយៈពេលខ្លី | | | |
|---|---|---|---|
| | ២០០៤ | ២០០៥ | ២០០៦ |
| **ទិសដៅជាយុទ្ធសាស្ត្រទី ៧ ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសម្រេច** | | | |
| ៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិស័យយុត្តិធម៌ ដើម្បីវាស់វែងការអនុវត្តទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះ ដើម្បីជាមគ្គុទេសក៍សម្រាប់កំណែទម្រង់ទាំងមូល | →→→→→→→→→ →→→→→→→→→X | | |
| ៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសនវកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី ១) | →→→→→→→→→→→→→→→→→→→X | | |
| ៧.៥.២ ផែនការ ការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀត នៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ (ដំណាក់កាលទី ១) | →→→→→→→→→ →→→→→→→→→X | | |
| ៧.៧.១ កសាងសមត្ថភាពចាំបាច់សម្រាប់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានមនុស្ស | →→→→→→→→→ →→→→→→→→→X | | |

## ទិសដៅជាយុទ្ធសាស្ត្រទី ៧

### អាទិភាពកំណត់៖

៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិសយ័យុត្តិធមិ ដើម្បីវាស់វែងការអនុវត្តទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះ ដើម្បីជាមគ្គុទេសក៍សម្រាប់កំណែទម្រង់ទាំងមូល

៧.៥.១ ការអភិវឌ្ឍនិងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការកម្មរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ដំណាក់កាលទី១)

៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ (ដំណាក់កាលទី១)

៧.៧.១ កសាងសមត្ថភាពចាំបាច់របស់ស្ថាប័ននីមួយៗ ដើម្បីបំពេញអណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងធនធានមនុស្ស

<table>
<tr><td colspan="3">ទិសដៅជាយុទ្ធសាស្ត្រៈ ពង្រឹងស្ថាប័នវិស័យយុត្តិធម៌ ដើម្បីបំពេញអាណត្តិរបស់ស្ថាប័នទាំងនោះ</td><td colspan="3">លទ្ធផលរំពឹងទុក ៖ សមត្ថភាព និងមធ្យោបាយត្រូវបានផ្តល់នៅក្នុងវិស័យផែនការកម្ម និងធ្វើថវិកាត្រួតពិនិត្យតាមដានមើល និងការធ្វើរបាយការណ៍ ដើម្បីធ្វើឱ្យការអនុវត្ត មានការទទួលខុសត្រូវមានប្រសិទ្ធភាព និងគ្រប់គ្រាន់</td></tr>
<tr><th>សកម្មភាពជាអាទិភាព</th><th>ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ</th><th>ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ</th><th>រយៈពេល</th><th>សកម្មភាពដែលត្រូវធ្វើ</th><th>សេចក្តីសង្កេតបន្ថែម</th></tr>
<tr><td colspan="6">៧.៤ វិស័យយុត្តិធម៌គួរអភិវឌ្ឍន៍នូវប្រព័ន្ធត្រួតពិនិត្យដែលអាចវាស់វែងនូវរបៀបដែលអនុវត្តរកយុត្តិធម៌ (រួមទាំងវិធាននានា ដំណើរការ ស្ថាប័ន និងយន្តការនៃការអនុវត្ត ដើម្បីរកយុត្តិធម៌) ហើយនៅក្នុងពេលជាមួយគ្នានេះដែរ បង្ហាញពីបញ្ហា និងកត្តារាំងស្ទះឯទៀតនៅក្នុងការគ្រប់គ្រប់រដ្ឋបាលយុត្តិធម៌</td></tr>
<tr><td>៧.៤.១ បង្កើតប្រព័ន្ធពិនិត្យតាមដាននៃវិស័យយុត្តិធម៌ ដើម្បីវាស់វែងការអនុវត្តរទូទៅ រួមទាំងរដ្ឋបាលនៃវិស័យនេះ ដើម្បីជាមគ្គុទេសក៍សម្រាប់កំណែទម្រង់ទាំងមូល</td><td>ក.ក.ច.ន.យ<br>ក្រ.យុត្តិធម៌<br>ឧត្តម.ចៅក្រម<br>ក្រ.មហាផ្ទៃ<br>(នគរបាល + ពន្ធនាគារ)</td><td>Aus-Aid</td><td>២០០៤-២០០៦</td><td>១-ផ្អែកលើផែនការសកម្មភាព រៀបចំសូចនាករនៃការអនុវត្តសម្រាប់ប្រព័ន្ធយុត្តិធម៌ និងកំណត់មធ្យោបាយសម្រាប់ប្រមូលទិន្នន័យ និងធ្វើរបាយការណ៍<br>២- ផ្តួចផ្តើមការពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ស្ថាប័ននីមួយៗ ក៏ដូចជាសម្រាប់វិស័យយុត្តិធម៌ទាំងមូល ផ្សារភ្ជាប់ទៅ នឹងថវិការដ្ឋ</td><td></td></tr>
<tr><td colspan="6">៧.៥ វិស័យយុត្តិធម៌គួរអភិវឌ្ឍន៍ និងរក្សានូវផែនការកម្ម ថវិកាកម្ម និងសវនកម្មមួយ ប្រព័ន្ធតាមដានត្រួតពិនិត្យគម្រោងនានាពាក់ព័ន្ធ និងធ្វើរបាយការណ៍ និងយុត្តិសាស្ត្រ រួមទាំងប្រព័ន្ធផែនការការងារ ៣ ឆ្នាំ ភ្ជាប់ និងគោរពទៅតាមផែនការកម្មរាជរដ្ឋាភិបាល និងប្រព័ន្ធក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ ភាសាគ្រប់គ្រងរួមបែបនេះ នឹងគាំទ្រសហប្រតិបត្តិការរវាងស្ថាប័ន នឹងអាចឱ្យវិស័យនេះសម្រេចអំពីអាទិភាព ដោយមិនបង្កគ្រោះថ្នាក់ដល់ឯករាជ្យភាពនៃស្ថាប័ននីមួយៗ ស្របទៅតាមតម្លៃនៃវិស័យយុត្តិធម៌ និងអាណត្តិស្ថាប័ន ។</td></tr>
</table>

| | | | | | |
|---|---|---|---|---|---|
| ៧.៥.១ ការអភិវឌ្ឍ និងការរក្សានូវប្រព័ន្ធរួមមួយអំពីការធ្វើផែនការ ការរៀបចំថវិកា និងសវនកម្ម ការតាមដាន និងការធ្វើរបាយការណ៍ ស្របទៅតាមផែនការកម្មរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម | ក.ក.ច.ន.យ<br>ក្រ.សេដ្ឋ.ហិរ<br>វិទ្យាស្ថានស្ថិតិ<br>ក្រ.ផែនការ | DIHR<br>Aus-Aid | ដំណាក់កាលទី១<br>២០០៤-២០០៦<br>(ដំណាក់កាលទី២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១- អភិវឌ្ឍន៏មូលដ្ឋានផែនការកម្មមួយលើយន្តការផែនការកម្មដែលមានសព្វថ្ងៃក្នុងក្របខ័ណ្ឌនៃវិស័យយុត្តិធមិ កំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ដទៃទៀត រួមទាំង MTEF ផង។<br>២- ធ្វើការស្ទង់មតិអំពីសេចក្តីត្រូវការផ្នែកបណ្តុះបណ្តាល (ចំពោះមន្ត្រីសំខាន់ៗផ្នែកគ្រប់គ្រងនៅតាមស្ថាប័ននីមួយៗនៃវិស័យយុត្តិធមិ)<br>៣- ការអភិវឌ្ឍសៀវភៅបង្រៀនរួមមួយសម្រាប់ស្ថាប័នវិស័យយុត្តិធមិអំពីយន្តការ និងវិធីសាស្ត្រធ្វើផែនការ ធ្វើកម្មវិធី រៀបចំថវិកា តាមដាន ធ្វើសវនកម្ម និងធ្វើរបាយ-ការណ៍ | DIHR បានផ្តើមកិច្ចពិភាក្សាអំពីគម្រោងឧបត្ថម្ភ PCB និង PMU ក្នុងផ្នែកនេះ។ គម្រោងឧបត្ថម្ភភ្ជាប់ទៅនឹងគម្រោងឧបត្ថម្ភរបស់ AusAid / CCJAP ក្នុងសកម្មភាព ៧.៥.២ |

| | | | | | |
|---|---|---|---|---|---|
| ៧.៥.២ ផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័ន្ធផ្សេងៗទៀតនៃវិស័យច្បាប់ និងតុលាការ រួមទាំងសាលារៀនរបស់វិស័យច្បាប់ និងតុលាការ | ក.ក.ច.ន.យ<br>ក្រ.យុត្តិធមិ<br>ក្រ.មហាផ្ទៃ<br>សាលាបណ្តុះបណ្តាល | DIHR<br>Aus-Aid | ដំណាក់កាលទី ១ ២០០៤-២០០៦ (ដំណាក់កាលទី២ សូមអានកម្មវិធីរយៈពេលមធ្យម) | ១-ផ្តល់ការបណ្តុះបណ្តាលជូនស្ថាប័នយុត្តិធមិ អំពីយន្តការ និងវិធីសាស្ត្រធ្វើផែនការ រៀបចំថវិកា តាមដាន ធ្វើសវនកម្ម និងរបាយការណ៍<br>២-រៀបចំផែនការការងារសម្រាប់នគរបាល ប្រព័ន្ធពន្ធនាគារ អយ្យការ រដ្ឋបាលតុលាការ និងស្ថាប័នវិស័យយុត្តធមិផ្សេងទៀតរួមទាំងសាលាបណ្តុះបណ្តាលវិស័យនេះផង | AusAid បានជួយឧបត្ថម្ភក្រសួងយុត្តិធមិ និងក្រសួងមហាផ្ទៃ (នាយកដ្ឋានពន្ធនាគារ) និង PMU ក្នុងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ និងកម្មវិធីថវិកា ។ គម្រោងឧបត្ថម្ភនេះភ្ជាប់ជាមួយ និងសកម្មភាព ៧.៥.១ |
| ៧.៧ អភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានមនុស្សដែលគួសបញ្ជាក់ពីការជ្រើសរើស និងគោលនយោបាយអាជីព និងសេចក្តីណែនាំដែលពាក់ព័ន្ធ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការតែងតាំង ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ ការផ្លាស់ប្តូរ ការដាក់វិន័យគោលនយោបាយ បណ្តុះបណ្តាល និងការវាយតម្លៃ សេចក្តីត្រូវការជាប្រព័ន្ធដែលពាក់ព័ន្ធ និងកម្មវិធីបណ្តុះបណ្តាលនៅក្នុងវិស័យដូចតទៅ ការបញ្ចូលដល់និយោជិតថ្មី ការបណ្តុះបណ្តាលនិយោជិតដែលតម្លើងឋានៈថ្មី និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការបណ្តុះបណ្តាលជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ និងការយល់ដឹងទូទៅ និងការអនុវត្តក្រមសីលធមិ ។ ជាចុងក្រោយ គោលនយោបាយគួររួមបញ្ចូលនូវប្រព័ន្ធតម្លាភាព ដាក់វិន័យនូវរបៀបឱ្យស្ថាប័នប្រឆាំងនឹងអំពើពុករលួយ និងជំរុញឱ្យប្រសើរឡើងនូវសីលធមិ ។ | | | | | |
| ៧.៧.១ កសាងសមត្ថភាពចាំបាច់របស់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍគោលនយេបាយគ្រប់គ្រងធនធានមនុស្ស | ក.ក.ច.ន.យ<br>ក្រ.យុត្តិធមិ<br>ឧត្តម.ចៅក្រម<br>ក្រ.មហាផ្ទៃ<br>(នគរបាល + ពន្ធនាគារ)<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល-មេធាវី<br>ក.ក.វ | DIHR<br>Aus-Aid | ២០០៤-២០០៦ | ១- ពង្រឹង PMU& PCB ពាក់ព័ន្ធដល់ការងារសម្របសម្រួល និងតួនាទីលេខា-ធិការដ្ឋាន ក្នុងដំណើរការកែទម្រង់ (សូមអានសកម្មភាព ៧.៦.២)<br>២- អភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធាុស្ស និងផែនការសកម្មភាព | |